អាជ្ញាធរមីន
C.M.A.A

# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ទី២៣

# កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ខែធ្នូ ឆ្នាំ២០២៤

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣កែង៥១៦ សង្កាត់ទួលសង្កែ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១|០២៣-៨៨១-៤៩២
ទូរសារ: +885-23-881-308
អ៊ីមែល: info@cmaa.gov.kh
គេហទំព័រ: www.cmaa.gov.kh

# ការរក្សាសិទ្ធិ

ឯកសារនេះ គឺជាស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា (CMAS) ដែលត្រូវបានរក្សាសិទ្ធិ។ ហាមយកឯកសារនេះ ទាំងស្រុង ឬផ្នែកណាមួយនៃឯកសារនេះ ទៅផលិតឡើងវិញ រក្សាទុក ឬចែកចាយក្នុងទម្រង់ណាមួយ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមីន។

ឯកសារនេះអាចទទួលបានពីអាជ្ញាធរមីន និងមិនសម្រាប់លក់។

# មាតិកា


**អារម្ភកថា** .......... 1
**សេចក្តីផ្តើម** .......... 2
**កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ** .......... 4
**១. វិសាលភាព** .......... 4
**២. ឯកសារយោង** .......... 4
**៣. វាក្យសព្ទ និងនិយមន័យ** .......... 4
**៤. គោលការណ៍កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ** .......... 6
**៥. សមាសធាតុនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ** .......... 9
៥.១. ការប្រមូលទិន្នន័យ .......... 9
៥.២. ការសង្គ្រោះបន្ទាន់ និងថែទាំសុខភាពបន្ត .......... 10
៥.៣. ការស្តារលទ្ធភាពពលកម្មកាយសម្បទា .......... 10
៥.៤. ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម .......... 10
៥.៥. បរិយាបន្នសេដ្ឋកិច្ច-សង្គម .......... 11
៥.៦. ច្បាប់ និងគោលនយោបាយ .......... 12
**៦. តួនាទី និងការទទួលខុសត្រូវ** .......... 12
៦.១. វិស័យសកម្មភាពមីនក្នុងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ .......... 12
៦.២. កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះរបស់អាជ្ញាធរមីន .......... 13
៦.៣. ប្រតិបត្តិករសកម្មភាពមីន និងអង្គការដៃគូផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ .......... 15
៦.៤. អង្គការសហប្រជាជាតិ .......... 18
៦.៥. អង្គការផ្សេងៗ .......... 18
៦.៦. អង្គការអ្នករស់រានមានជីវិត និងអង្គភាពតំណាងរបស់ពួកគាត់ .......... 19
**៧. សេចក្តីសន្និដ្ឋាន** .......... 19
ឧបសម្ព័ន្ធ១៖ កំណត់ត្រាអំពីការកែលម្អកំណត់ត្រាអំពីការកែលម្អ .......... 21
ឧបសម្ព័ន្ធ២៖ ឯកសារយោង .......... 22

## អក្សរបំព្រួញ

| | |
|---|---|
| BLS | ការស្រាវជ្រាវមូលដ្ឋាន |
| DPO | អង្គការជនពិការ |
| CMAA | អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការដោយសារមីន |
| CMAC | មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា |
| CMAS | ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា |
| CMAMIS | ប្រព័ន្ធគ្រប់គ្រងទិន្នន័យសកម្មភាពមីនកម្ពុជា |
| CMVIS | ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយសារមីន/ស.ផ.ស |
| DBU | អង្គភាពគ្រប់គ្រងទិន្នន័យ |
| EO | គ្រាប់យុទ្ធភណ្ឌគ្រឿងផ្ទុះ |
| ERW | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| IMAS | ស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ |
| MAPU | អង្គការផែនការសកម្មភាពកំចាត់មីនខេត្ត |
| MDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MRE | ការអប់រំយល់ដឹងអំពីមីន |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NMAS | ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន |
| PMAC | គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត |
| PRC | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា |
| PWD | ជនមានពិការភាព |
| PWDF | មូលនិធិជនពិការ |
| QA | ការធានាគុណភាព |
| QC | ការត្រួតពិនិត្យគុណភាព |
| QMT | ក្រុមត្រួតពិនិត្យគុណភាព |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SADD | ការញែកទិន្នន័យ ភេទ អាយុ |
| SDG | គោលដៅអភិវឌ្ឍប្រកបដោយចីរភាព |
| SOP | ស្តង់ដាបទដ្ឋានប្រតិបត្តិការ |
| VA | កិច្ចសង្គ្រោះជនរងគ្រោះ |
| VSN | បណ្តាញអ្នកស្ម័គ្រចិត្តជនពិការ |
| UN | អង្គការសហប្រជាជាតិ |

## អារម្ភកថា

ស្តង់ដាអន្តរជាតិសម្រាប់ការបោសសម្អាតមីនមនុស្សធម៌ ត្រូវបានស្នើឡើងដោយក្រុមការងារក្នុងសន្និសីទបច្ចេកទេសអន្តរជាតិជាលើកដំបូងនៅក្នុងប្រទេសដាណឺម៉ាក ក្នុងខែកក្កដា ឆ្នាំ១៩៩៦។ ជាលទ្ធផល លក្ខខណ្ឌនៃការបោសសម្អាតមីន ការបង្កើតស្តង់ដា និងនិយមន័យនៃការបោសសម្អាតមីនជាសកលត្រូវបានពិភាក្សា និងឯកភាព។ នៅចុងឆ្នាំ១៩៩៦ ស្តង់ដាអន្តរជាតិសម្រាប់ការបោសសម្អាតមីនមនុស្សធម៌ត្រូវបានបង្កើតឡើងដោយក្រុមការងារដែលដឹកនាំដោយអង្គការសហប្រជាជាតិ ដោយផ្អែកលើគោលការណ៍ដែលបានឯកភាពនៅប្រទេសដាណឺម៉ាក។ ស្តង់ដាអន្តរជាតិសម្រាប់ប្រតិបត្តិការបោសសម្អាតមីនមនុស្សធម៌ត្រូវបានបោះពុម្ពជាលើកដំបូងដោយភ្នាក់ងារសេវាកម្មសកម្មភាពមីនរបស់អង្គការសហប្រជាជាតិនៅខែមីនា ឆ្នាំ១៩៩៧។

ចាប់តាំងពីពេលនោះមក វិសាលភាពនៃស្តង់ដាដើមត្រូវបានពង្រីក ដើម្បីដាក់បញ្ចូលផ្នែកផ្សេងៗនៃសកម្មភាពមីន ក្នុងគោលបំណងដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃនីតិវិធីប្រតិបត្តិការ ការអនុវត្ត និងបទដ្ឋាននានា។ ស្តង់ដាអន្តរជាតិសម្រាប់ប្រតិបត្តិការបោសសម្អាតមីនមនុស្សធម៌ ត្រូវបានកែសម្រួល និងប្តូរឈ្មោះទៅជាស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ ដែលបានបោះពុម្ពជាលើកដំបូងនៅក្នុងខែតុលា ឆ្នាំ២០០១។

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន មានតួនាទីក្នុងការបង្កើត កែសម្រួល និងថែរក្សាស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ដោយផ្អែកលើស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ និងឧត្តមានុវត្តន៍នានា។ ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជាកំណត់នូវលក្ខខណ្ឌតម្រូវអប្បបរមា និងផ្តល់នូវក្របខណ្ឌច្បាប់សម្រាប់ប្រតិបត្តិករសកម្មភាពមីន ដើម្បីរៀបចំស្តង់ដាបទដ្ឋានប្រតិបត្តិការ ធានាឱ្យបាននូវសុវត្ថិភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងសម្របសម្រួលដល់ការអនុវត្តសកម្មភាពមីននានា ហើយស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជាត្រូវបង្កើតឡើងជាលើកដំបូងក្នុងឆ្នាំ២០០៥។

អាជ្ញាធរមីន មានតួនាទី និងភារកិច្ចក្នុងការបង្កើតស្តង់ដា ដោយធ្វើការពិគ្រោះយោបល់ជាមួយប្រតិបត្តិករសកម្មភាពមីន ដើម្បីធានាបាននូវការអនុវត្តការងារឱ្យមានភាពរលូន។ នៅពេលសេចក្តីព្រាងស្តង់ដាត្រូវបានរៀបចំឡើងអាជ្ញាធរមីននឹងចែករំលែកសេចក្តីព្រាងជាមួយសមាជិកគណៈកម្មការត្រួតពិនិត្យ និងកែសម្រួលស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ដឹកនាំដោយអាជ្ញាធរមីន និងមានការចូលរួមពីប្រតិបត្តិករសកម្មភាពមីនដែលជាសមាជិក ដើម្បីធ្វើការពិនិត្យ និងផ្តល់ធាតុចូល។ អាជ្ញាធរមីន មានតួនាទីក្នុងការសម្រេចចុងក្រោយលើស្តង់ដាដែលមានថ្នាក់ដឹកនាំអាជ្ញាធរមីនជាអ្នកអនុម័តលើស្តង់ដាទាំងអស់ ដែលដំណើរការបង្កើត និងការកែសម្រួលស្តង់ដានឹងត្រូវអនុវត្តតាមលំនាំនេះ។

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ មានគោលបំណងលុបបំបាត់នូវទុក្ខលំបាករបស់ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គ្រួសារ និងសហគមន៍របស់ពួកគាត់។

បញ្ហាគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម( ស.ផ.ស. ) នៅកម្ពុជាដែលបង្កឡើងដោយសារសង្គ្រាមជម្លោះផ្ទៃក្នុង និងក្នុងតំបន់ដែលអូសបន្លាយពេលយ៉ាងយូរ ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ចុងឆ្នាំ១៩៩៨។ ស្ថានភាពទូទៅនៃបញ្ហាគ្រាប់មីន និងស.ផ.ស. នៅកម្ពុជា មានលក្ខណៈស្មុគស្មាញយ៉ាងខ្លាំង ដោយសារតែកង្វះខាតកំណត់ត្រាព័ត៌មានអំពីកន្លែងបង្កប់គ្រាប់មីន ជម្លោះប្រដាប់អាវុធជាបន្តបន្ទាប់ និងការទម្លាក់គ្រាប់បែក។ ប្រជាជនកម្ពុជានៅតែបន្តរងផលប៉ះពាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលជាឧបសគ្គរារាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយបរិយាបន្ន រារាំងឱកាសស្មើភាពគ្នា និងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងធ្វើឱ្យកើនឡើងនូវជនមានពិការភាព។ សម្រាប់អ្នកដែលរស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ បានធ្វើឱ្យសុវត្ថិភាពផ្លូវកាយ និងផ្លូវអារម្មណ៍របស់ពួកគេ នៅតែបន្តប្រឈមនឹងហានិភ័យ។

បន្ទាប់ពីបានជួបឧបទ្ទវហេតុគ្រោះថ្នាក់កើតឡើង ជនរងគ្រោះមានការរងទុក្ខទាំងផ្លូវកាយ ផ្លូវអារម្មណ៍ ផ្លូវចិត្ត និងជួបវិបត្តិផ្នែកហិរញ្ញវត្ថុ ដែលការទទួលរងទុក្ខនេះ ទាមទារឱ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រ ការស្តារលទ្ធភាពពលកម្ម និងការគាំពារផ្នែកសង្គម ដើម្បីឱ្យពួកគាត់ជាសះស្បើយបន្ទាប់ពីរងគ្រោះថ្នាក់។ អំឡុងពេលសរសេរស្តង់ដានេះឡើង គឺយោងទៅតាមប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន/ស.ផ.ស. ដែលបានកត់ត្រាចាប់ពីឆ្នាំ១៩៧៩ ដល់ខែវិច្ឆិកា ឆ្នាំ២០២៤ មានអ្នកស្លាប់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៦៥.០៨៤ នាក់ ជនរងគ្រោះបានស្លាប់មានចំនួន ១៩.៨៣៣ នាក់ រងរបួសមានចំនួន ៣៦.១៥៥ នាក់ និងជនរងគ្រោះធ្លាក់ខ្លួនពិការមានចំនួន ៩.០៩៦ នាក់។ ដែលតួលេខទាំងនេះមិនបានបញ្ជាក់ពីចំនួនអ្នកដែលរងការប៉ះទង្គិចផ្លូវចិត្តក្រោយជួបឧបទ្ទវហេតុគ្រោះថ្នាក់ និងស្ថានភាពសុខភាពផ្លូវចិត្តយូរអង្វែងនោះឡើយ។

ការរៀបចំស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវបានគិតគូរលើកដំបូង ដោយក្រុមការងារសម្របសម្រួលអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិសកម្មភាពមីនក្នុងឆ្នាំ២០០១។ ហើយស្តង់ដាសកម្មភាពមីនអន្តរជាតិលេខ ១៣.១ ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារ

យុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវបានបោះពុម្ពលើកទី១ ជាផ្លូវការនៅក្នុងខែកញ្ញា ឆ្នាំ២០២១។ ស្របតាមស្តង់ដានេះ អាជ្ញាធរមីនបានរៀបចំស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជាទី២៣ ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដើម្បីឱ្យប្រតិបត្តិករអនុវត្តកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះអាចបន្តធ្វើបច្ចុប្បន្នភាពលើស្តង់ដាឱ្យស្របតាមបរិបទជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា។

គោលបំណងនៃការបង្កើតស្តង់ដា គឺដើម្បីផ្តល់នូវគោលការណ៍ជាមូលដ្ឋាននៃការរៀបចំកម្មវិធីឆ្លើយតបទៅនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅកម្ពុជា។ ស្តង់ដានេះរួមបញ្ចូលនូវគោលនយោបាយ និងគោលការណ៍អនុវត្ត ដើម្បីធានាថា កម្មវិធីឆ្លើយតបទៅនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវបានអនុវត្តប្រកបដោយនិរន្តរភាព។ ដូចគ្នានេះ ក៏អាចផ្តល់ជាមូលដ្ឋានសម្រាប់កសាងភាពជាដៃគូរៀបចំគម្រោងកម្មវិធី និងជាយន្តការសម្របសម្រួលក្នុងការផ្តល់សេវាកម្មរវាងរាជរដ្ឋាភិបាល ស្ថាប័នផ្តល់សេវាកម្ម

ប្រទេស ឬស្ថាប័នផ្តល់ជំនួយ និងអង្គការអនុវត្តគម្រោង។

ស្តង់ដានេះ ក៏បានបញ្ជាក់ពីគោលការណ៍ តួនាទី និងការទទួលខុសត្រូវលើការងារកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដោយផ្តោតទៅលើសកម្មភាពសំខាន់ៗ ដូចជា ការប្រមូលទិន្នន័យ ការសង្គ្រោះបន្ទាន់ និងថែទាំសុខភាពបន្ត ការស្តារលទ្ធភាពពលកម្ម ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម បរិយាបន្នសេដ្ឋកិច្ច-សង្គម និងការរៀបចំច្បាប់ គោលនយោបាយ សម្រាប់វិស័យមកពីគ្រប់ភាគីពាក់ព័ន្ធ។ ជាមួយគ្នានេះស្តង់ដាសកម្មភាពមីនកម្ពុជាក៏ជាឧបករណ៍មួយ ដើម្បីជួយក្នុងការរៀបចំស្តង់ដាបទដ្ឋានប្រតិបត្តិការផងដែរ។

# កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

## ១. វិសាលភាព

ស្តង់ដា បានដាក់ចេញនូវគោលការណ៍ និងក្របខ័ណ្ឌសំខាន់ៗសម្រាប់ការគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព ការរៀបចំផែនការ ការចាត់អាទិភាព ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃសកម្មភាពនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅកម្ពុជា ជាពិសេស បញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធរមីន ប្រតិបត្តិករសកម្មភាពមីន អង្គការដៃគូជាតិ/អន្តរជាតិ ស្ថាប័នផ្តល់សេវាកម្មកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ អង្គការជួយអ្នករស់រានមានជីវិត និងអង្គការតំណាងរបស់ពួកគេ ក៏ដូចជាក្រសួង និងស្ថាប័នពាក់ព័ន្ធមួយចំនួនដូចជា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាសកម្មភាពជនពិការ និងមូលនិធិជនពិការ។ ស្តង់ដានេះ ក៏ជាឯកសារក្របខណ្ឌថ្នាក់ជាតិសម្រាប់ប្រតិបត្តិករសកម្មភាពមីន និងប្រតិបត្តិករផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ព្រមទាំងភាគីពាក់ព័ន្ធសម្រាប់ប្រើប្រាស់ និងអនុវត្ត។ ស្តង់ដានេះផងដែរក៏មានគោលបំណងផ្តល់ជាគោលការណ៍ណែនាំ ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដើម្បីបំពេញនូវតម្រូវការ និងការឆ្លើយតបទៅនឹងសិទ្ធិរបស់ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិសកម្មភាពមីន ក៏ដូចជាច្បាប់ និងគោលនយោបាយផ្សេងៗទៀតរបស់កម្ពុជា។

## ២. ឯកសារយោង

បញ្ជីឯកសារយោងនានាមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ"ក"។ ឯកសារយោងទាំងនោះ គឺជាឯកសារដ៏សំខាន់ដែលត្រូវបានប្រើប្រាស់សម្រាប់រៀបចំផ្នែកណាមួយ ឬខ្លឹមសារទាំងមូលនៃស្តង់ដានេះ។

## ៣. វាក្យសព្ទ និងនិយមន័យ

ពាក្យគន្លឹះនឹងត្រូវបានប្រើជាញឹកញាប់នៅក្នុងឯកសារនេះ ដែលត្រូវបានរៀបរាប់ដូចខាងក្រោម៖

- "**ត្រូវតែ**" ត្រូវបានប្រើដើម្បីបញ្ជាក់ពីតម្រូវការចាំបាច់ វិធីសាស្ត្រ ឬភាពជាក់លាក់ ដែលត្រូវអនុវត្តឱ្យស្របទៅនឹង ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា
- "**គួរតែ**" ត្រូវបានប្រើដើម្បីបញ្ជាក់ពីតម្រូវការ វិធីសាស្ត្រ ឬភាពជាក់លាក់ផ្សេងៗទៀតដែលបានស្នើឡើង
- "**អាច**" ត្រូវបានប្រើដើម្បីបញ្ជាក់ពីវិធីសាស្ត្រ ឬមធ្យោបាយដែលអាចទទួលយកបាន។
- "**យុទ្ធភណ្ឌគ្រឿងផ្ទុះ**" សំដៅលើគ្រាប់ដែលមានផ្ទុករំសេវផ្ទុះ រួមមាន៖ មីន គ្រាប់បែកចង្កោម គ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះ គ្រាប់យុទ្ធភណ្ឌបោះបង់ចោល ខ្សែអន្ទាក់បង្កៃ គ្រាប់កែច្នៃ និងគ្រាប់ផ្សេងៗទៀត ដូចបានកំណត់ដោយវិសោធនកម្មពិធីសារ២នៃអនុសញ្ញាសព្វាវុធធម្មតា។
- "**កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ**" សំដៅលើកិច្ចខិតខំប្រឹងប្រែងទូលំទូលាយ និងជាក់លាក់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងសិទ្ធិរបស់ជនរងគ្រោះ។

**<u>ពន្យល់បន្ថែម៖</u>**

១-កិច្ចខិតខំប្រឹងប្រែងទូលំទូលាយរបស់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គឺជាកិច្ចខិតខំប្រឹងប្រែង ដែលធ្វើឡើងដោយវិស័យផ្សេងទៀតក្រៅពីវិស័យសកម្មភាពមីន រួមទាំងការផ្តល់សេវា និងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ការប្រមូលទិន្នន័យ ការសម្របសម្រួល និងការរៀបចំច្បាប់ និងគោលនយោបាយ។

២-កិច្ចខិតខំប្រឹងប្រែងជាក់លាក់របស់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គឺជាកិច្ចខិតខំប្រឹងប្រែងដែលធ្វើឡើងដោយវិស័យសកម្មភាពមីន ដើម្បីរួមចំណែកក្នុងការសម្របសម្រួលដល់ការទទួលបានសេវាកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ សេវាកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ រួមមាន៖ ការសង្គ្រោះបន្ទាន់ និងថែទាំសុខភាពបន្ត ការស្តារលទ្ធភាពពលកម្មកាយសម្បទា ការគាំទ្រផ្លូវចិត្តនិងចិត្តសង្គម បរិយាបន្នសេដ្ឋកិច្ច-សង្គម ច្បាប់ និងគោលនយោបាយ។

- **"ជនរងគ្រោះ"** សំដៅលើបុគ្គលម្នាក់ៗ ឬជាសមូហភាព ដែលធ្លាប់មានរបួសផ្លូវកាយ អារម្មណ៍ និងផ្លូវចិត្ត និងបាត់បង់សេដ្ឋកិច្ចព្រមទាំងសិទ្ធិមូលដ្ឋាន តាមរយៈសកម្មភាពទាក់ទងនឹងការប្រើប្រាស់យុទ្ធភណ្ឌគ្រឿងផ្ទុះ។ ជនរងគ្រោះ រួមមាន៖ អ្នករងរបួស ពិការ និងស្លាប់(ដោយផ្ទាល់ ឬដោយប្រយោល) ក្រុមគ្រួសាររបស់ពួកគេ និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។
- **"ពាក្យជនរងគ្រោះដោយផ្ទាល់"** សំដៅលើមនុស្សស្លាប់ របួស និងពិការដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។
- **"អ្នករស់រានមានជីវិត"** សំដៅលើជនរងគ្រោះដោយផ្ទាល់ដែលបានរងរបួស ឬពិការ ប៉ុន្តែមិនបានស្លាប់ដោយសាររងគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។
- **"ជនរងគ្រោះដោយប្រយោល"** សំដៅលើសមាជិកគ្រួសារនៃជនរងគ្រោះដោយផ្ទាល់ ក៏ដូចជាបុគ្គល និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។
- **"អង្គការអ្នករស់រានមានជីវិត"** សំដៅលើអង្គការដែលជាតំណាង និងធ្វើការដើម្បីផលប្រយោជន៍របស់អ្នករស់រានមានជីវិត និងជនមានពិការភាព និងជនរងគ្រោះដោយប្រយោល រួមទាំងអ្នករស់រានមានជីវិត និងជនរងគ្រោះដោយប្រយោលនៅក្នុងរចនាសម្ព័ន្ធប្រតិបត្តិការរបស់ខ្លួន។ អង្គការអ្នករស់រានមានជីវិតត្រូវបានបង្កើតឡើងសម្រាប់ផ្តល់នូវអត្ថប្រយោជន៍ដល់ជនរងគ្រោះ ហើយជារឿយៗរួមចំណែកដល់ការគាំទ្រ និងការបញ្ជូនបន្តដោយផ្អែកលើបទពិសោធន៍ និងផ្តល់សេវាកម្មទៅតាមតម្រូវការរបស់ជនរងគ្រោះអាចត្រូវបានដោះស្រាយ។ ជាធម្មតា ការតស៊ូមតិត្រូវបានដឹកនាំដោយអ្នករស់រានមានជីវិត ការលើកកម្ពស់ការយល់ដឹង ការចល័តសហគមន៍ និងរួមចំណែកដល់ការសម្របសម្រួលផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។
- **"អង្គការដៃគូ"** សំដៅលើអង្គការដែលបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ឬកិច្ចព្រមព្រៀងអនុវត្តការងារជាមួយអាជ្ញាធរមីន។ អង្គការដៃគូតាមរយៈការគាំទ្រទៅវិញទៅមក ការសហការ និងកិច្ចសហប្រតិបត្តិការ ធ្វើការរួមគ្នាដើម្បីសម្រេចបាននូវគោលដៅរួមនៃវិស័យសកម្មភាពមីន និងសកម្មភាពផ្តល់ជំនួយដល់ជនរងគ្រោះដោយសារគ្រាប់មីន/ស.ផ.ស រួមទាំងគ្រួសាររបស់ពួកគេ និងជនមានពិការភាពផ្សេងទៀត។
- **"បញ្ជូន"** សំដៅលើការផ្តល់ព័ត៌មានអំពីសេវាដែលមានដល់ជនរងគ្រោះ។

- "**យន្តការបញ្ជូនបន្ត**" សំដៅលើប្រព័ន្ធសម្រាប់កំណត់អត្តសញ្ញាណ កិច្ចការពារ និងជួយជនរងគ្រោះដែលរងរបួសដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ អ្នករស់រានមានជីវិត ជនមានពិការភាព និងជនរងគ្រោះដោយប្រយោល ហើយភ្ជាប់ពួកគេទៅកាន់សេវាផ្ដល់ជំនួយដល់ជនរងគ្រោះដែលត្រូវការ (ឬផ្តល់ឱ្យពួកគេនូវ"ព័ត៌មានអំពីសេវាកម្មដែលមាន")។
- "**បរិយាបន្នសេដ្ឋកិច្ច-សង្គម**" សំដៅលើការអប់រំប្រកបដោយបរិយាបន្ន និងបរិយាបន្នសេដ្ឋកិច្ច ដូចជា ការផ្តល់ប្រាក់ឈ្នួលស្មើគ្នា ផ្តល់យុត្តិធម៌ និងឱកាសសម្រាប់ទទួលការងារសមរម្យ ក៏ដូចជា ការបណ្តុះបណ្តាលជំនាញ ការអប់រំវិជ្ជាជីវៈ កិច្ចគាំពារសង្គម ការងារប្រកបដោយនិរន្តរភាព ក៏ដូចជាការធ្វើការងារដោយខ្លួនឯង និងរួមបញ្ចូលកិច្ចគាំពារសង្គមផងដែរ។

## ៤. គោលការណ៍កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

មូលដ្ឋានគ្រឹះនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គឺជាគោលការណ៍មនុស្សធម៌នៃមនុស្សជាតិ អព្យាក្រឹតភាព ភាពមិនលម្អៀង និងឯករាជ្យភាព។ រាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងដៃគូពាក់ព័ន្ធយល់ថា ជនងាយរងគ្រោះត្រូវការការគាំទ្រទូទាំងប្រទេស ហើយសកម្មភាពកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវការយកចិត្តទុកដាក់ជាពិសេស។ ដូចនេះ សកម្មភាពកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវបានអនុវត្តដោយអនុលោមតាមច្បាប់សិទ្ធិមនុស្សថ្នាក់ជាតិ និងអន្តរជាតិ ស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ និងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា។ បន្ថែមពីលើគោលការណ៍មនុស្សធម៌របស់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលបានរៀបរាប់ខាងលើ ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក៏ត្រូវបានអនុវត្តតាមគោលការណ៍ទូទៅដូចខាងក្រោម ៖

**ការមិនរើសអើង**៖ គឺជាកិច្ចខិតខំប្រឹងប្រែងរបស់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ មិនគួរមានការរើសអើងចំពោះជនរងគ្រោះណាមួយក្នុងចំណោមជនរងគ្រោះ ឬការរើសអើងរវាងជនរងគ្រោះ និងជនរងគ្រោះផ្សេងទៀត ក៏ដូចជា អ្នកដែលរងរបួស ឬជនមានពិការភាពដោយសារមូលហេតុផ្សេងៗ។ ការជ្រើសរើសវិធីសាស្ត្រក្នុងការព្យាបាល គួរផ្អែកលើតម្រូវការផ្នែកវេជ្ជសាស្ត្រ ការស្តារលទ្ធភាពពលកម្ម ការគាំទ្រផ្លូវចិត្ត ឬតម្រូវការសេដ្ឋកិច្ច-សង្គមរបស់ជនរងគ្រោះ រួមទាំងការស្នាក់នៅសមរម្យ។ កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក៏មិនគួររើសអើងលើមូលដ្ឋាននៃកត្តាភាពចម្រុះផ្សេងទៀត ដូចជា ពិការភាព ភេទ អាយុ ជាតិសាសន៍ ពូជសាសន៍ សាសនា ភាសា ស្ថានភាពសេដ្ឋកិច្ច-សង្គម ឬអត្តសញ្ញាណផ្សេងៗទៀត។

**លើកកម្ពស់ការចូលរួម និងបរិយាបន្ន**៖ ជនរងគ្រោះ និងអង្គការតំណាងគួរតែត្រូវបានពិគ្រោះ និងផ្តល់ការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តសម្រាប់រៀបចំច្បាប់ គោលនយោបាយ និងកម្មវិធី ក្នុងគោលបំណងលើកកម្ពស់ការធ្វើបរិយាបន្នសេដ្ឋកិច្ច-សង្គម។

**ផាសុកវត្ថុ**៖ អ្នករស់រានមានជីវិត ជនមានពិការភាពផ្សេងទៀត និងជនរងគ្រោះដោយប្រយោល គួរតែទទួលបានការផ្តល់សេវាកម្មទៅតាមលក្ខខណ្ឌតម្រូវដែលបានកំណត់។ ប្រសិនបើមានឧបសគ្គរាំងក្នុងការទទួលបានសេវាដែលមានស្រាប់ បញ្ហាទាំងនោះគួរតែត្រូវបានដោះស្រាយជាប្រព័ន្ធ។ ឧបសគ្គទាំងនេះអាចទាក់ទងទៅនឹងកង្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ហិរញ្ញវត្ថុ ឌីជីថល ការធ្វើដំណើរមកទទួលសេវាកម្ម ទីតាំងមិនអំណោយផល

ភាសាខុសគ្នា និងការគិតគូរផ្នែកផ្លូវច្បាប់ ក៏ដូចជា អាយុ ភេទ ពិការភាព និងបទដ្ឋានវប្បធម៌ ក្នុងចំណោមកត្តាផ្សេងទៀត ដែលអាចដាក់កម្រិតលើការចូលរួមក្នុងសេវាកម្មផ្តល់ជំនួយដល់ជនរងគ្រោះ និងចំពោះទីកន្លែងស្នាក់នៅសមរម្យក៏គួរតែត្រូវបានផ្តល់ជូនដល់ពួកគេផងដែរ។

**<u>ភាពងាយរងគ្រោះ</u>**៖ ក្រសួង ស្ថាប័ន ត្រូវស្វែងយល់អំពីផលប៉ះពាល់លើជនរងគ្រោះ (គ្រួសារ និងសហគមន៍របស់ពួកគេ) ដោយសារលក្ខខណ្ឌបរិស្ថាន និងសង្គមអាចបង្កើនភាពងាយរងគ្រោះ ហើយត្រូវរិះរកមធ្យោបាយកាត់បន្ថយភាពងាយរងគ្រោះ និងការរងទុក្ខតាមដែលអាចធ្វើទៅបាន ដូចជា ការគាំទ្រផ្នែកហិរញ្ញវត្ថុ ការចូលរួមក្នុងសង្គម និងការពង្រឹងកាយសម្បទា។

**ភាពងាយរងគ្រោះ៖** ស្ថានភាពបរិស្ថាន និងសង្គមកាន់តែទូលំទូលាយដែលអាចកំណត់សមត្ថភាពជនរងគ្រោះ និងអ្នករស់រានមានជីវិត ក៏ដូចជា កម្រិតយល់ដឹងរបស់ជនមានពិការភាពក្នុងការទប់ទល់នឹងផលប៉ះពាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ កត្តាបរិស្ថាន និងផ្នត់គំនិតអាចធ្វើឱ្យជនរងគ្រោះ និងជនមានពិការភាពផ្សេងទៀត អាចប្រឈមនឹងភាពងាយរងគ្រោះ ហើយកត្តាទាំងនេះគួរត្រូវបានពិចារណាដាក់បញ្ចូលក្នុងកម្មវិធីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

**<u>ការគិតគូរលើភាពចម្រុះ</u>**៖ អាយុ យេនឌ័រ ពិការភាព អត្តសញ្ញាណផ្លូវភេទ និងភាពចម្រុះផ្សេងទៀតគួរតែត្រូវបានគិតគូរនៅពេលរៀបចំផែនការផ្តល់សេវាកម្ម ដូចនេះ ការប្រមូលទិន្នន័យបែងចែកតាមភេទ អាយុ និងប្រភេទពិការភាព គឺជាសកម្មភាពដ៏សំខាន់។ ទិន្នន័យទាំងនេះគួរតែត្រូវបានពិនិត្យ និងរួមបញ្ចូលកត្តាសំខាន់ៗផ្សេងទៀត ដើម្បីយល់ពីការផ្តល់សេវាដល់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះយ៉ាងពេញលេញ។ អាយុ ភេទ ពិការភាព អត្តសញ្ញាណផ្លូវភេទ តម្រូវការ និងបទពិសោធន៍ចម្រុះផ្សេងទៀតរបស់ជនរងគ្រោះ គួរតែត្រូវបានពិចារណានៅក្នុងការរៀបចំផែនការ នៃកិច្ចខិតខំប្រឹងប្រែងរបស់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ ត្រូវតែរៀបចំសេវាកម្មឱ្យស្របទៅតាមតម្រូវការ ដើម្បីឆ្លើយតបទៅនឹងភាពចម្រុះរបស់ពួកគាត់។ ដើម្បីគាំទ្រដល់ការធ្វើផែនការកម្មវិធីប្រកបដោយប្រសិទ្ធភាព ទិន្នន័យជនរងគ្រោះ ដែលត្រូវបានគេស្គាល់ជាទូទៅថា ជាទិន្នន័យជនរងគ្រោះ នឹងត្រូវបែងចែកតាមភេទ អាយុ និងពិការភាព ដើម្បីធានាបាននូវទិន្នន័យថាតើជនរងគ្រោះមានពិការភាពប្រភេទណាមួយ មុនពេលមានគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

**<u>និរន្តរភាព និងភាពជាម្ចាស់</u>**៖ កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គឺជាសកម្មភាពមានរយៈពេលវែង ដូចនេះ ត្រូវរៀបចំរាល់សេវាកម្មកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គោលនយោបាយ ផែនការសកម្មភាព និងផែនការហិរញ្ញវត្ថុឱ្យបានសមរម្យ ប្រកបដោយនិរន្តភាព និងត្រូវបានអនុវត្តនៅកម្រិតថ្នាក់ជាតិ។

**<u>អភិក្រមសិទ្ធិជាមូលដ្ឋាន</u>**៖ កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធគ្រឿងផ្ទុះ ត្រូវតែអនុវត្តតាមច្បាប់សិទ្ធិមនុស្សទាំងថ្នាក់ជាតិ និងអន្តរជាតិ។ ជនរងគ្រោះគួរតែទទួលបានសេវាសុខភាពដែលមានលក្ខណៈស្តង់ដាសមរម្យ សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ការអប់រំប្រកបដោយបរិយាបន្ន ការងារសមរម្យ ការចូលរួមពេញលេញ និងបរិយាបន្នក្នុងសង្គម ការរស់នៅដែលមានស្តង់ដាសមរម្យ និងកិច្ចគាំពារសង្គម។ ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងភាពជាអ្នកដឹកនាំ គឺចាំបាច់សម្រាប់ការអនុវត្តដោយជោគជ័យនូវគោលការណ៍របស់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ ដើម្បីឱ្យគោលការណ៍ទាំងនេះ ត្រូវអនុវត្តនៅក្នុងប្រទេសកម្ពុជា គួរតែមានការ

ធ្វើសមកាលកម្មអន្តរវិស័យ។ រាជរដ្ឋាភិបាលកម្ពុជា និងវិស័យពិការភាពនៅកម្ពុជា គួរតែជាអ្នកដឹកនាំ ក្នុងការធ្វើសមកាលកម្មអន្តរវិស័យសម្រាប់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

**<u>ការអនុវត្តផ្អែកលើភស្តុតាង</u>៖** ការអនុវត្តផ្អែកលើភស្តុតាងត្រូវបានអនុវត្តក្នុងការផ្តល់សេវាកម្មកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលមានឯកទេសសុខាភិបាលសមរម្យដោយផ្អែកលើការសិក្សាដោយមានភស្តុតាងត្រឹមត្រូវ និងទិន្នន័យនៃការថែទាំអ្នកជំងឺពីអ្នកឯកទេសសុខាភិបាល ក៏ដូចជាតម្រូវការរបស់អ្នកជំងឺ។ គោលបំណងនៃការអនុវត្តនេះ គឺដើម្បីផ្តល់នូវសេវាថែទាំសុខភាពប្រកបដោយគុណភាព ការគ្រប់គ្រងសេវាកម្មប្រកបដោយប្រសិទ្ធភាពរបស់អង្គការ ដោយផ្អែកលើទិន្នន័យជាក់លាក់ក្នុងការសម្រេចបាននូវលទ្ធផលដ៏ល្អប្រសើរសម្រាប់ជនរងគ្រោះ។ **គោលការណ៍ដែលត្រូវអនុវត្តពេលធ្វើការជាមួយជនរងគ្រោះ៖**

**<u>ស្ថាប័នពាក់ព័ន្ធ</u>៖**

- ឥរិយាបទចំពោះជនរងគ្រោះត្រូវស្មើភាពគ្នាប្រកបដោយសេចក្តីថ្លៃថ្នូរ មានការគោរព ផ្តល់ក្តីមេត្តា និងបានគិតគូរទៅតាមអាយុ វប្បធម៌ ជាតិសាសន៍ និងទំនោរផ្លូវភេទ
- ត្រូវតែគោរព និងរក្សាការសម្ងាត់របស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ដោយធ្វើការស្នើសុំការអនុញ្ញាតពីជនរងគ្រោះមុនពេលធ្វើសកម្មភាពណាមួយ(ទោះបីជាសកម្មភាពនៃការប្រមូល និងចែករំលែកទិន្នន័យ) គោរពក្នុងការជ្រើសរើស និងការសម្រេចចិត្តរបស់ជនរងគ្រោះ
- ត្រូវតែឱ្យអាទិភាពជាចម្បងលើសុវត្ថិភាពជនរងគ្រោះ ក្រុមគ្រួសារ និងសមាជិកសហគមន៍របស់ពួកគាត់ នៅពេលដែលធ្វើការសម្ភាសត្រូវមានលក្ខណៈឯកជន ដោយរក្សាការសម្ងាត់ និងសុខសុវត្ថិភាពរបស់ពួកគាត់។ ជាមួយគ្នានេះ ត្រូវពិចារណាដោយប្រុងប្រយ័ត្ននូវស្ថានភាពដែលអាចកើតមានឡើងដែលបង្កការគំរាមកំហែងដល់សុខសុវត្ថិភាពរបស់ជនរងគ្រោះ
- ត្រូវចងចាំជានិច្ចថា ក្នុងពេលបញ្ជូនជនរងគ្រោះទៅទទួលសេវាកម្មផ្សេងៗទៀត មានកត្តាមួយចំនួនដែលធ្វើឱ្យមានការរារាំងដល់ជនរងគ្រោះក្នុងការទៅទទួលសេវាក្នុងនោះរួមមាន៖ កង្វះខាតថវិកាមធ្យោបាយធ្វើដំណើរ និងលទ្ធភាពធ្វើដំណើរ ព្យាយាមកំណត់ប្រព័ន្ធ និងច្រកទទួលសេវាកម្ម ដែលនៅជិតបំផុត ព្រមទាំងការផ្តល់ព័ត៌មាន និងមានការណែនាំឱ្យបានច្បាស់លាស់
- ត្រូវតែពន្យល់ឱ្យបានច្បាស់លាស់ដល់ជនរងគ្រោះពីដំណើរការនៃប្រព័ន្ធ និងច្រកទទួលសេវាកម្ម ព្រមទាំងពេលវេលាផងដែរ ជៀសវាងការសន្យាដែលមិនប្រាកដប្រជាអំពីលទ្ធភាពនៃការបញ្ជូនជនរងគ្រោះទៅទទួលសេវាកម្ម
- គួរតែចាត់ទុកវិស័យពិការភាព គឺជាវិស័យដែលមានកត្តាចម្រុះ ដែលធ្វើឱ្យមានភាពស្មុគស្មាញជាពិសេស គឺភាពប្រទាក់ក្រឡារវាងកិច្ចគាំពារ វិស័យសុខាភិបាល និងលក្ខខណ្ឌសេដ្ឋកិច្ច-សង្គម។ ដូចនេះ ស្ថាប័នពាក់ព័ន្ធគួរតែកំណត់ប្រព័ន្ធ និងច្រកទទួលសេវាកម្មឱ្យអស់លទ្ធភាព ដើម្បីធានាថាជនរងគ្រោះទទួលបានសេវាកម្មមានរយៈពេលមធ្យម និងរយៈពេលវែង
- គួរតែសម្របសម្រួលជាមួយភាគីពាក់ព័ន្ធផ្សេងទៀត ក្នុងការបញ្ជូនជនរងគ្រោះ និងចែករំលែកព័ត៌មានជាមួយស្ថាប័នផ្តល់សេវាកម្មជនរងគ្រោះ។ ស្ថាប័នពាក់ព័ន្ធគួរតែផ្តល់ព័ត៌មានថ្មីៗជាប្រចាំដល់ជនរងគ្រោះ និងបណ្តាញរបស់ពួកគាត់

- គួរតែកែសម្រួលប្រព័ន្ធនិងច្រកទទួលសេវាកម្មដែលមានស្រាប់ និងចៀសវាងការប្រើប្រាស់ប្រព័ន្ធផ្សេងគ្នា ហើយស្ថាប័នពាក់ព័ន្ធគួរតែប្រើប្រាស់ និងដាក់បញ្ចូលសកម្មភាពរបស់ខ្លួននៅក្នុងប្រព័ន្ធ និងច្រកទទួលសេវាកម្មដែលកំពុងប្រើប្រាស់ដោយអាជ្ញាធរ និងសហគមន៍មនុស្សធម៌ ។

## ៥. សមាសធាតុនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

សមាសធាតុនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ រួមមាន៖

ក. ការប្រមូលទិន្នន័យ

ខ. ការសង្គ្រោះបន្ទាន់ និងថែទាំសុខភាពបន្ត

គ. ការស្តារលទ្ធភាពពលកម្ម

ឃ. ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម

ង. បរិយាបន្នសេដ្ឋកិច្ច-សង្គម

ច. ច្បាប់ និងគោលនយោបាយ។

### ៥.១. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យរួមមាន ការប្រមូល ការវិភាគ និងការចែករំលែកព័ត៌មាន ដើម្បីឱ្យបានដឹង រាយការណ៍ និងផ្សព្វផ្សាយព័ត៌មានដូចខាងក្រោម ៖

- ប្រមូលទិន្នន័យជនរងគ្រោះដោយបែងចែកតាម ភេទ អាយុ និងប្រភេទពិការភាព ដោយប្រើប្រាស់កម្រងសំណួរដែលមានប្រសិទ្ធភាពនៅក្នុងបរិបទមនុស្សធម៌។ ក្នុងចំណោមនោះរួមមាន៖ កម្រងសំណួរ Washington Group Short Set និង UNICEF-Washington Group Module ស្តីពីសុខមាលភាពកុមារដែលបំពេញបន្ថែមឱ្យកម្រងសំណួរដែលមានស្រាប់ក្នុងការកំណត់អត្តសញ្ញាណពិការភាព
- ប្រមូលទិន្នន័យអំពីសេវាកម្មដែលមានស្រាប់ ដើម្បីគាំទ្រដល់ការបញ្ជូនជនរងគ្រោះទៅទទួលសេវាកម្ម ហើយជនរងគ្រោះភាគច្រើន មានទីលំនៅរស់នៅក្នុងតំបន់ជនបទដាច់ស្រយាលឆ្ងាយពីរាជធានី/ខេត្ត ដែលស្ថាប័ន អង្គការផ្តល់សេវាកម្មភាគច្រើន មិនបានទៅដល់ទីតាំងជនរងគ្រោះកំពុងរស់នៅ ហើយក៏មានកត្តាជាច្រើនជាឧបសគ្គរាំងដល់ជនរងគ្រោះមកទទួលសេវាកម្ម ក្នុងនោះមាន៖ ពេលវេលា ថវិកាធ្វើដំណើរ កង្វះខាតកន្លែងថែទាំកុមារ កន្លែងស្នាក់នៅ កង្វះខាតព័ត៌មាន កង្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងឥរិយាបថរើសអើងជាដើម។ ការកំណត់អត្តសញ្ញាណជនរងគ្រោះនៅកន្លែងដែលពួកគាត់កំពុងរស់នៅ និងគាំទ្រពួកគាត់ឱ្យទទួលបានសេវាកម្ម គឺជាជំហានដ៏សំខាន់មួយក្នុងការធានាឱ្យមានការលើកកម្ពស់ការចូលរួម និងគុណភាពជីវិតប្រសើរឡើង

នៅក្នុងប្រទេសកម្ពុជា អាជ្ញាធរមីន មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា មេភូមិ និងមេឃុំ គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត អង្គភាពផែនការសកម្មភាពមីន អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញអ្នកស្ម័គ្រចិត្តជនពិការ គឺជាភាគីពាក់ព័ន្ធដែលធ្វើការប្រមូលទិន្នន័យនៅទីវាល។ ការប្រមូលទិន្នន័យ គឺជាកត្តាសំខាន់ក្នុងការស្វែងយល់ការធ្វើផែនការ និងការត្រួតពិនិត្យសកម្មភាពរបស់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ ដូចនេះ ដំណើរការនៃការប្រមូលទិន្នន័យទាមទារឱ្យមានលក្ខណៈស្តង់ដាច្បាស់លាស់។

## ៥.២. ការសង្គ្រោះបន្ទាន់ និងថែទាំសុខភាពបន្ត

ការសង្គ្រោះបន្ទាន់ និងថែទាំសុខភាពបន្ត គឺមានសារៈសំខាន់ ក្នុងនោះរួមមាន៖ ការសង្គ្រោះបឋម ការជម្លៀសបន្ទាន់ និងការព្យាបាលផ្នែកវេជ្ជសាស្ត្ររួមទាំងការវះកាត់ ការបញ្ចូលឈាម ការគ្រប់គ្រងការឈឺចាប់ និងសេវាសុខភាពផ្សេងទៀតដែលផ្តល់ដោយក្រុមគ្រូពេទ្យឯកទេសពហុជំនាញ។ ការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពចាំបាច់ត្រូវតែធ្វើឡើងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាផ្នែកមួយនៃប្រព័ន្ធសុខាភិបាលនៅកម្ពុជា។

## ៥.៣. ការស្តារលទ្ធភាពពលកម្មកាយសម្បទា

អនុលោមតាមនិយមន័យរបស់អង្គការសុខភាពពិភពលោក និងភ្នាក់ងារប្រឹក្សាយោបល់ថ្នាក់តំបន់ ការស្តារលទ្ធភាពពលកម្មកាយសម្បទា គឺជាកិច្ចការងារមួយដែលត្រូវបានរៀបចំឡើងដើម្បីពង្រឹងសុខមាលភាព និងកាត់បន្ថយផ្នែកពិការភាពដោយផ្អែកលើលក្ខខណ្ឌសុខភាពរបស់ជនរងគ្រោះម្នាក់ៗ។ ជាទូទៅការស្តារលទ្ធភាពពលកម្មកាយសម្បទា មានគោលបំណងធ្វើអោយសុខមាលភាពរបស់ជនរងគ្រោះត្រឡប់មកដូច "ធម្មតា" វិញ។

ការស្តារលទ្ធភាពពលកម្មកាយសម្បទា មិនសំដៅតែទៅលើបញ្ហាសុខភាព និងការបន្លាស់ទីនោះទេ ប៉ុន្តែរួមទាំងផ្នែកផ្លូវចិត្ត ចិត្តសង្គម ហិរញ្ញវត្ថុ ការអប់រំ និងការធ្វើបរិយាបន្នចូលក្នុងសង្គមដល់ជនរងគ្រោះ។ តាមរយៈការស្តារលទ្ធភាពពលកម្ម ជនរងគ្រោះ គ្រួសារ និងសហគមន៍របស់ពួកគាត់ ដែលអាចស្វែងយល់ពីវិធីដោះស្រាយការរស់នៅប្រចាំថ្ងៃជាមួយនឹងតម្រូវការសម្រាប់ឆ្លើយតបទៅនឹងស្ថានភាពសុខភាពរបស់ពួកគាត់។

គោលបំណងសំខាន់មួយនៃការស្តារលទ្ធភាពពលកម្មកាយសម្បទា គឺដើម្បីធ្វើអោយប្រសើរឡើងនូវសុខមាលភាព និងការបម្លាស់ទី ដោយលុបបំបាត់ ឬកាត់បន្ថយការឈឺចាប់ ដើម្បីឱ្យជនរងគ្រោះអាចត្រឡប់ទៅជីវភាពរស់នៅធម្មតាវិញ តាមរយៈការស្តារលទ្ធភាពពលកម្មកាយសម្បទា ក៏ដូចជាការគាំទ្រសុខភាពផ្លូវចិត្ត និងសតិបញ្ញា។ ការស្តារលទ្ធភាពពលកម្មកាយសម្បទា ជាទូទៅគឺជាផ្នែកមួយដ៏សំខាន់នៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងក្របខណ្ឌវិស័យសុខាភិបាល ក្នុងនោះរួមមានបញ្ចូលទាំងការពិនិត្យ ការវាយតម្លៃ ការបំពាក់ ការផ្គត់ផ្គង់ និងការថែទាំអវយវៈសិប្បនិម្មិត និងរណប ការព្យាបាលដោយចលនា និងការហ្វឹកហ្វឺនក្នុងការប្រើឧបករណ៍ជំនួយក្នុងការដើរ និងរទេះរុញជាដើម។ ការស្តារលទ្ធភាពពលកម្មកាយសម្បទា ជាទូទៅតម្រូវឱ្យមានក្រុមគ្រូពេទ្យឯកទេសពហុជំនាញ ដែលមានវេជ្ជបណ្ឌិត អ្នកជំនាញផលិតអវយវៈសប្បនិម្មិត និងរណប គិលានុបដ្ឋាយិកា អ្នកជំនាញព្យាបាលដោយចលនា និងអ្នកជំនាញព្យាបាល ។

## ៥.៤. ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម

ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម គឺជាផ្នែកមួយដ៏សំខាន់នៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលមានដូចជា ប្រព័ន្ធប្រឹក្សាយោបល់ផ្លូវការសម្រាប់ការព្យាបាលផ្លូវចិត្ត និងសតិបញ្ញា ដោយវេជ្ជបណ្ឌិត អ្នកចិត្តសាស្ត្រ អ្នកប្រឹក្សាយោបល់ និងបុគ្គលិកធ្វើការងារសង្គម។ លើសពីនេះ ប្រព័ន្ធប្រឹក្សាយោបល់ក្រៅផ្លូវការនៅក្នុងសហគមន៍ ដូចជា សមាជិកគ្រួសារ ព្រឹទ្ធាចារ្យ ព្រះសង្ឃ និងគ្រូបុរាណ(គ្រូខ្មែរ)។

ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម មានដូចជា៖

- ការគាំទ្រផ្លូវចិត្តតាមរយៈប្រព័ន្ធ និងច្រកទទួលសេវាកម្មផ្លូវការ
- ការគាំទ្រផ្លូវចិត្តពីមន្ទីរពេទ្យ

- ការគាំទ្រផ្លូវចិត្តពីបុគ្គលិកធ្វើការងារសង្គម អ្នកចិត្តសាស្ត្រ និងអ្នកជំនាញព្យាបាលជំងឺផ្លូវចិត្ត
- ការគាំទ្រផ្លូវចិត្តពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា
- បណ្តាញគាំទ្រមិត្តសម្រាប់សុខមាលភាពសង្គម និងអារម្មណ៍
- រៀបចំវេទិកាសាធារណៈដើម្បីឱ្យមានសម្លេងសហគមន៍ ឱ្យគេស្តាប់លឺ និងអាចចូលរួមក្នុងសង្គម
- ការគាំទ្រផ្លូវចិត្តតាមរយៈមិត្តអប់រំមិត្តៈ ផ្តល់ការគាំទ្រផ្នែកសង្គម និងផ្លូវអារម្មណ៍ ដោយជនរងគ្រោះដែលមានស្ថានភាពគ្រោះថ្នាក់ និងបញ្ហាប្រឈមប្រហាក់ប្រហែលគ្នា តាមរយៈការប្រឹក្សាយោបល់មួយទល់មួយ ឬក្រុមគាំទ្រការងារសង្គម
- សកម្មភាពវប្បធម៌ កីឡា និងសកម្មភាពកំសាន្ត ដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសុខមាលភាពផ្លូវចិត្ត និងទំនាក់ទំនងសហគមន៍។

### ៥.៥. បរិយាបន្នសេដ្ឋកិច្ច-សង្គម

បរិយាបន្នសេដ្ឋកិច្ច-សង្គម គឺពាក់ព័ន្ធទៅនឹងការអប់រំ ការអភិវឌ្ឍជំនាញ កិច្ចគាំពារសង្គម ការទទួលបានការងារ និងបរិយាបន្នសង្គម។ សមាសភាគសំខាន់ៗនៃបរិយាបន្នសង្គម រួមមាន៖ ការគាំទ្រសង្គម ការគាំទ្រសម្រាប់ទំនាក់ទំនងល្អក្នុងជីវិតគ្រួសារ ទំនាក់ទំនងជាវិជ្ជមាន សុខភាពគ្រួសារ និងឥរិយាបទសហគមន៍ ការបង្ការ និងដោះស្រាយអំពើហិង្សាលើអ្នករស់រានមានជីវិត។ លើសពីនេះ សម្រាប់បរិយាបន្នសង្គម ធ្វើឱ្យជនរងគ្រោះមានឱកាសស្មើៗគ្នាក្នុងការចូលរួមសកម្មភាពនានាដូចជា វប្បធម៌ កីឡា និងការកំសាន្ត។

សកម្មភាពសំខាន់ៗនៃបរិយាបន្នសេដ្ឋកិច្ច គឺតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ការទទួលបានឥណទានខ្នាតតូច ការបង្កើតប្រាក់ចំណូល និងឱកាសការងារ កិច្ចគាំពារសង្គមនិងសន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ចលើហេដ្ឋារចនាសម្ព័ន្ធសហគមន៍។ ចំណុចសំខាន់នៃបរិយាបន្នសេដ្ឋកិច្ច-សង្គម គឺការអប់រំប្រកបដោយបរិយាបន្ន ការលើកកម្ពស់ការចូលរួមក្នុងការអប់រំ ដោយឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកសិក្សារៀនសូត្រ ជាពិសេសជនងាយរងគ្រោះ រួមទាំងជនមានពិការភាព។ ការអប់រំប្រកបដោយបរិយាបន្ន គឺជាសិទ្ធិមូលដ្ឋាន ដែលធ្វើឱ្យជនរងគ្រោះទទួលបានចំណេះដឹង ក្នុងការទទួលបានសិទ្ធិផ្សេងៗទៀតដូចជា ការថែទាំសុខភាព ទទួលបានការងារ និងការចូលរួមការងារនយោបាយ។

**សមាសភាគនៃការអប់រំមាន៖**

- ការថែទាំកុមារតូច និងការអប់រំ
- ការអប់រំនៅថ្នាក់បឋមសិក្សា
- ការអប់រំនៅថ្នាក់មធ្យមសិក្សា និងឧត្តមសិក្សា
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មសិក្សា
- ការអប់រំក្រៅប្រព័ន្ធ
- ការរៀនសូត្រពេញមួយជីវិត

កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវការផ្តល់ការគាំទ្រ និងមានការចូលរួមនៅគ្រប់កម្រិតនៃការអប់រំ។

### ៥.៦. ច្បាប់ និងគោលនយោបាយ

ការរៀបចំគម្រោងកម្មវិធីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គួរតែអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ដើម្បីធានាថា ជនរងគ្រោះទទួលបានសិទ្ធិសមរម្យ។ សិទ្ធិទាំងនេះ ធានាថា ជនរងគ្រោះមានឱកាសស្មើគ្នានៅក្នុងសង្គម ក្នុងនោះរួមមាន ការទទួលបានសេវាសុខាភិបាល ការអប់រំ ឱកាសការងារ កិច្ចគាំពារសង្គម និងបរិយាបន្នពិការភាព។ ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គឺជាក្របខ័ណ្ឌសម្រាប់អនុវត្តកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូចនេះ រាល់សកម្មភាពទាំងអស់ ត្រូវអនុវត្តឱ្យស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលអាចគ្របដណ្តប់លើបញ្ហាទូទៅដូចជា សុវត្ថិភាព និងសុខភាពការងារ លក្ខខណ្ឌតម្រូវក្នុងកិច្ចការពារបរិស្ថាន ការបង្កើតឱកាសស្មើភាពគ្នា និងជាពិសេស ច្បាប់ទាក់ទងនឹងជនមានពិការភាព។

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ត្រូវបានគ្របដណ្តប់លើផ្នែកសំខាន់ៗមួយចំនួនៈ

- ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ
- ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន
- អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្ម តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន
- អនុក្រឹត្យស្តីពីការកំណត់អត្រា និងបែបបទនៃការជ្រើសជនពិការចូលបម្រើការងារ
- អនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍
- ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម
- បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។

## ៦. តួនាទី និងការទទួលខុសត្រូវ

### ៦.១. វិស័យសកម្មភាពមីនក្នុងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

តួនាទីចម្បងនៃវិស័យសកម្មភាពមីន គួរតែជាកិច្ចសហការ និងមានគោលបំណងក្នុងការសម្របសម្រួលការផ្តល់នូវកម្មវិធីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះថ្នាក់ជាតិ។ "វិធីសាស្ត្ររួមបញ្ចូលគ្នា" គួរតែត្រូវបានពិចារណា និងដាក់រួមបញ្ចូលគ្នាលើការគាំទ្រអន្តរវិស័យ។

កត្តាសំខាន់ៗមួយចំនួននៃវិធីសាស្ត្ររួមបញ្ចូលគ្នា (គ្របដណ្តប់លើឯកសារនេះ) គឺៈ

- ការគ្រប់គ្រងព័ត៌មាន រួមទាំងការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងការចែករំលែកទិន្នន័យ
- វិធីសាស្ត្រច្បាស់លាស់ក្នុងការបញ្ជូនជនរងគ្រោះទៅទទួលសេវារបស់រដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាល
- ការលើកកម្ពស់ និងធ្វើការត្រួតពិនិត្យទំនាក់ទំនងជាមួយអន្តរវិស័យ និងសេវាកម្មគាំទ្រ
- ផែនការសកម្មភាពថ្នាក់ជាតិ និងធនធាន ដើម្បីគាំទ្រដល់ផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

- **គាំទ្រការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះការផ្តល់ជំនួយដល់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ**៖វិស័យសកម្មភាពមីនគួរតែជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធដើម្បីធានាថា មានសេវាកម្មគ្រប់គ្រាន់ និងអាចប្រើប្រាស់បានសម្រាប់ជនរងគ្រោះ និងសហគមន៍។
- **លើកកម្ពស់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះទៅក្នុងកម្មវិធីសកម្មភាពមីន៖** វិស័យសកម្មភាពមីន គួរតែលើកកម្ពស់ឱ្យរួមបញ្ចូលកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះទៅក្នុងវិស័យសុខាភិបាល ពិការភាព ការអប់រំ ការងារ ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ដែលជាការចាំបាច់តម្រូវឱ្យកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវបានដាក់បញ្ចូលយ៉ាងពេញលេញទៅក្នុងវិស័យផ្សេងទៀត។

## ៦.២. កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះរបស់អាជ្ញាធរមីន

អាជ្ញាធរមីនទទួលខុសត្រូវចំពោះបទប្បញ្ញត្តិ ការគ្រប់គ្រង ការត្រួតពិនិត្យ ការវាយតម្លៃ ការសម្របសម្រួល និងការបង្កើតក្របខណ្ឌថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដែលអាចឱ្យការគ្រប់គ្រង និងការគាំទ្រកម្មវិធីសកម្មភាពមីននៅកម្ពុជាអនុវត្តប្រកបដោយប្រសិទ្ធភាព។ អាជ្ញាធរមីន ទទួលខុសត្រូវលើគ្រប់សកម្មភាពមីន ធ្វើការត្រួតពិនិត្យលើសកម្មភាព និងធ្វើការគាំទ្រផ្នែកនានាដល់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

ការទទួលខុសត្រូវរបស់អាជ្ញាធរមីនមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី០៤ កញ្ញា ឆ្នាំ២០០០ និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០១។

អាជ្ញាធរមីន គួរតែធ្វើការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយគោលនយោបាយ គោលការណ៍ណែនាំ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់រដ្ឋាភិបាល ដែលទាក់ទងនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ជាពិសេស សម្រាប់ការយល់ដឹងអំពីតម្រូវការ នៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ការលើក

កម្ពស់សិទ្ធិជនរងគ្រោះ គោលនយោបាយថ្នាក់ជាតិ និងកម្មវិធីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ អាជ្ញាធរមីន គួរតែដឹកនាំបង្កើតឱ្យមានស្តង់ដាថ្នាក់ជាតិ ដែលបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវនៃវិធីសាស្ត្រអន្តរវិស័យចំពោះការគាំទ្រ លើផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ និងលើកកម្ពស់ច្បាប់ជាតិ និងអន្តរជាតិ ដែលឆ្លើយតបទៅនឹងតម្រូវការ និងសិទ្ធិរបស់ជនរងគ្រោះ រៀបចំផែនការសកម្មភាពថ្នាក់ជាតិរួមជាមួយនឹងការអភិវឌ្ឍ និងការអនុវត្តកម្មវិធីដើម្បីពង្រឹងសមត្ថភាពលើផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅគ្រប់កម្រិត។

ក្នុងការអនុវត្តការងារកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ អាជ្ញាធរមីនគួរតែធ្វើការតាមដានការងារជាមួយស្ថាប័នពាក់ព័ន្ធដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាសកម្មភាពជនពិការ មូលនិធិជនពិការ និងអង្គការ សមាគមបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាស្ថាប័នជាតិ និងអន្តរជាតិ។ នៅក្នុងខណៈពេលដែលការគ្រប់គ្រង ការសម្របសម្រួល និងការធ្វើការតាមដានសេវាកម្មផ្តល់ជូនដល់ជនរងគ្រោះគឺជាទទួលខុសត្រូវរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ និងអង្គការពាក់ព័ន្ធ អាជ្ញាធរមីនគួរតែផ្តល់ជាមតិកែលម្អលើផ្នែកជំនាញក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ កម្មវិធី និងការធ្វើរបាយការណ៍ឱ្យបានសមស្រប។

ក្នុងនាមជាអាជ្ញាធរជាតិ អាជ្ញាធរមីនគួរតែរៀបចំធ្វើការផ្សព្វផ្សាយ ចូលរួមក្នុងព្រឹត្តិការណ៍ និងកិច្ចសន្ទនាលើផ្នែកពិការភាពថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីធានាឱ្យមានការគោរពសិទ្ធិ និងផ្តល់ឱកាសស្មើៗគ្នាសម្រាប់ជនរងគ្រោះ ដោយរួមបញ្ចូលទាំងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការកែលម្អ និងលើកកម្ពស់ការរៀបចំផែនការ និងកម្មវិធីសម្រាប់ផ្តល់ជំនួយដល់ផ្នែកពិការភាព ដែលតម្រូវឱ្យមានការលើកកម្ពស់ក្នុងការអនុវត្ត និងការចូលរួមធ្វើបរិយាបន្នសង្គមសម្រាប់ជនរងគ្រោះ ដំណើរការរៀបចំផែនការសហគមន៍ដែលជួយសម្របសម្រួលដល់ការចូលរួមរបស់ជនរងគ្រោះ និងជនមានពិការភាព និងការដាក់បញ្ចូលផ្នែកពិការភាពក្នុងការអប់រំសម្រាប់សហគមន៍ដើម្បីលើកកម្ពស់ការអនុវត្ត និងអាកប្បកិរិយាវិជ្ជមានចំពោះជនមានពិការភាព។

តាមរយៈភាពជាដៃគូរបស់អាជ្ញាធរមីន ជាមួយភាគីពាក់ព័ន្ធ អាជ្ញាធរមីនគួរតែចែករំលែកបញ្ជីសេវាកម្មជាមួយភាគីពាក់ព័ន្ធ ក៏ដូចជាជនរងគ្រោះ ព្រមទាំងបង្កើត និងផ្សព្វផ្សាយសេវាកម្មបញ្ជូនបន្តជាមួយភាគីពាក់ព័ន្ធក៏ដូចជាវិស័យនានា។ អាជ្ញាធរមីនគួរតែធ្វើការប្រមូល រក្សាទុក និងចែករំលែកទិន្នន័យស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ និងតម្រូវការរបស់ពួកគេ។ អាជ្ញាធរមីន គួរតែធ្វើការវិភាគទិន្នន័យដែលប្រមូលបានហើយធ្វើការចែករំលែកជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការបម្រើការងារវិស័យពិការភាពឱ្យស្របទៅនឹងបទប្បញ្ញត្តិស្តីពីកិច្ចការពារទិន្នន័យថ្នាក់ជាតិសម្រាប់ទិន្នន័យរបស់ជនរងគ្រោះ។

### ៦.២.១. ការទទួលខុសត្រូវក្នុងការសម្របសម្រួលសេវាកម្ម

អាជ្ញាធរមីនគួរតែបង្កើតក្របខណ្ឌថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានសម្រាប់អនុវត្តសកម្មភាព និងការផ្តល់សេវាកម្មលើផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះប្រកបដោយប្រសិទ្ធភាព។ អាជ្ញាធរមីនចាត់ទុកថាកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គឺជាផ្នែកមួយនៃសកម្មភាពមីន វាមិនមែនជាការខិតខំប្រឹងប្រែងដែលមានពេលវេលាកំណត់ ដូចជា ការអប់រំអំពីយុទ្ធភណ្ឌគ្រឿងផ្ទុះ ការស្រាវជ្រាវ និងការបោសសម្អាតមីននោះទេ ហើយវាក៏ជាផ្នែកមួយ និងពឹងផ្អែកលើគោលនយោបាយជាតិ ផែនការ និងក្របខ័ណ្ឌច្បាប់ដែលទាក់ទងទៅនឹងផ្នែកសុខភាព សិទ្ធិមនុស្ស ការអប់រំ ពិការភាព កម្លាំងពលកម្ម ការកាត់បន្ថយភាពក្រីក្រ និងកិច្ចគាំពារសង្គម។ ដូចនេះ ការអនុវត្តនូវសមាសធាតុផ្សេងៗនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ អាចសម្រេចទៅបានតែតាមរយៈវិធីសាស្ត្រអន្តរវិស័យតែប៉ុណ្ណោះ។

### ៦.២.២. ការត្រួតពិនិត្យ ការប្រមូលទិន្នន័យ និងការទទួលខុសត្រូវក្នុងការសម្របសម្រួល

- <u>**ការត្រួតពិនិត្យ**</u>

- អាជ្ញាធរមីន ត្រូវតែត្រួតពិនិត្យ និងគាំទ្រអង្គការដែលពាក់ព័ន្ធនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលជាផ្នែកមួយក្នុងការជួយ និងពិនិត្យមើលស្តង់ដាបទដ្ឋានប្រតិបត្តិការ និងការណែនាំដើម្បីធានាថា ស្តង់ដាស្របគ្នាជាមួយស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ ការគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ អង្គការពាណិជ្ជកម្មជាតិ អន្តរជាតិ និងស្ថាប័នថ្នាក់ជាតិ។

- អាជ្ញាធរមីន គួរតែដើរតួនាទីក្នុងការត្រួតពិនិត្យ ការធានាគុណភាព និងធ្វើការពិនិត្យមើលលើសកម្មភាព

នៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដោយជានានូវការប្រមូលទិន្នន័យ និងផ្តល់ជាមតិកែលម្អជាបន្តបន្ទាប់ទៅកាន់ស្ថាប័នរដ្ឋាភិបាល ប្រតិបត្តិករ និងអ្នកផ្តល់សេវាផ្សេងទៀតឱ្យសម្រេចបានដោយការចូលរួមជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ជនរងគ្រោះ និងជនមានពិការភាពក្នុងការផ្តល់មតិកែលម្អ និងការវាយតម្លៃលើស្តង់ដានៃការផ្តល់សេវាកម្ម។

- **<u>ការប្រមូលទិន្នន័យ</u>**

ការប្រមូលទិន្នន័យ គឺជាការវិភាគ និងការចែករំលែកព័ត៌មានដ៏មានសារៈសំខាន់សម្រាប់ការយល់ដឹង និងរាយការណ៍ពីសកម្មភាព និងសេវាកម្មនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ នាពេល បច្ចុប្បន្ន។ នីតិវិធីគ្រប់គ្រងព័ត៌មានគួរតែបញ្ចូលទិន្នន័យពី ភេទ អាយុ និងប្រភេទពិការភាព លើជនរងគ្រោះដោយប្រើប្រាស់ឧបករណ៍ផ្សេងៗ ដែលបានពិភាក្សានៅក្នុងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ ដូចនេះ អាជ្ញាធរមីន គួរតែបង្កើត និងផ្សព្វផ្សាយប្រព័ន្ធទិន្នន័យ និងមូលដ្ឋានទិន្នន័យដែលអាចរកបាន ដើម្បីគាំទ្រ និងសម្រួលដល់ការបញ្ជូនបន្តសម្រាប់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ សូមយោងទៅផ្នែក"ការប្រមូលទិន្នន័យ" នៅខាងក្រោមសមាសធាតុនៃកិច្ច សង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងឯកសារនេះសម្រាប់ព័ត៌មានលម្អិតអំពីប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរមីន។

- **<u>ការសម្របសម្រួល</u>**

អាជ្ញាធរមីនរួមជាមួយភាគីពាក់ព័ន្ធផ្សេងៗធានាថា កម្មវិធីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅកម្ពុជាត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងស្របតាមស្តង់ដាថ្នាក់ជាតិ និងគោលការណ៍ណែនាំ ចាប់ពីការរៀបចំផែនការ និងកម្មវិធី រហូតដល់ការគ្រប់គ្រងគុណភាពប្រកបដោយនិរន្តរភាព។ ការធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការ ការទំនាក់ទំនង និងយន្តការរាយការណ៍រវាងក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ គឺជាភាពចាំបាច់សម្រាប់អនុវត្តកម្មវិធីនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ដូចនេះ អាជ្ញាធរមីន ត្រូវដើរតួនាទីជាស្ថាប័នក្នុងការសម្របសម្រួល ដើម្បីធានាការអនុវត្តសកម្មភាពកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនីមួយៗ ដូចខាងក្រោម៖

**<u>សម្រាប់ការសង្គ្រោះបន្ទាន់ និងការថែទាំសុខភាពបន្ត៖</u>**

- ជំនាញសង្គ្រោះបឋម និងធនធាន
- ភាពជាដៃគូជាមួយមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា
- ភាពជាដៃគូជាមួយមណ្ឌលសុខភាព
- មន្ទីរពេទ្យរដ្ឋ និងឯកជន

## ៦.៣. ប្រតិបត្តិករសកម្មភាពមីន និងអង្គការដៃគូផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

### ៦.៣.១.គោលការណ៍ណែនាំទូទៅ សម្រាប់អង្គការជនរស់រានមានជីវិតក្នុងការអនុវត្តផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

គ្រប់អង្គភាព ស្ថាប័ន រួមទាំងប្រតិបត្តិករជាតិ អន្តរជាតិ និងអង្គការដៃគូផ្តល់សេវាកម្មដែលទាក់ទងនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះផ្សេងទៀត ត្រូវគោរពតាមការណែនាំជាទូទៅដូចខាងក្រោម៖

- ធានាថារាល់សកម្មភាពដែលពាក់ព័ន្ធនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ អនុលោមតាមស្តង់ដាថ្នាក់ជាតិ និងស្តង់ដាថ្នាក់អន្តរជាតិដែលអាចអនុវត្តបាន( ស្តង់ដាសំខាន់ៗមានយោងនៅក្នុងឯកសារនេះ )
- ធានាថា រាល់សកម្មភាពដែលពាក់ព័ន្ធនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ អនុលោមតាមគោលនយោបាយស្តីពីសុខភាព ការអប់រំ សិទ្ធិមនុស្ស និងសេដ្ឋកិច្ច-សង្គម(គោលការណ៍សំខាន់ៗមានយោងនៅក្នុងឯកសារនេះ )
- ចុះឈ្មោះជាមួយក្រសួង ឬស្ថាប័នរដ្ឋាភិបាល ដែលមានទំនាក់ទំនងជាមួយអាជ្ញាធរមីន អំពីសកម្មភាពនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារគ្រាប់យុទ្ធភណ្ឌគ្រឿងផ្ទុះ
- ទទួលបានការណែនាំពីអាជ្ញាធរមីន ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលត្រូវបានធ្វើឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ពិចារណាលើគោលនយោបាយ នីតិវិធី និងសេវាកម្មដែលគាំទ្រអន្តរវិស័យរួមបញ្ចូលគ្នានៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ (**<u>ចំណាំ</u>**៖ អាជ្ញាធរមីន មានធនធានចំណេះដឹងផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គោលនយោបាយ នីតិវិធី និងសេវាកម្ម និងអាចចែករំលែកជាមួយអង្គការដៃគូផ្សេងៗ )
- រៀបចំឯកសាររបាយការណ៍ កំណត់ត្រា និងទិន្នន័យផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះសម្រាប់អាជ្ញាធរមីន និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀតទៅតាមតម្រូវការដោយមានរួមបញ្ចូលទាំងការចែករំលែកបញ្ជីសេវាកម្ម និងការផ្តល់ទិន្នន័យប្រចាំត្រីមាស
- ចូលរួម និងចែករំលែកព័ត៌មានពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការងារកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ប៉ុន្តែមិនកំណត់ចំពោះសកម្មភាពការយល់ដឹងជាសាធារណៈសម្រាប់អ្នកផ្តល់សេវា ការប្រើប្រាស់យន្តការសហការគាំទ្រ និងទទួលបានអត្ថប្រយោជន៍ពីគ្នាទៅវិញទៅមក
- តំណាងអង្គការ គួរតែចូលរួមក្នុងក្រុមការងារគាំទ្របច្ចេកទេសដែលរៀបចំដោយអាជ្ញាធរមីន តំណាងពីប្រតិបត្តិករទាំងអស់ ត្រូវបានអញ្ជើញអោយចូលរួមក្នុងក្រុមការងារគាំទ្របច្ចេកទេស។

### ៦.៣.២. ប្រតិបត្តិករសកម្មភាពមីន

ប្រតិបត្តិករសកម្មភាពមីន មានការទទួលខុសត្រូវ និងភារកិច្ចជាច្រើន ដែលបានរៀបរាប់នៅក្នុងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ និងឯកសារផ្សេងទៀត។ សកម្មភាពរបស់ប្រតិបត្តិករសកម្មភាពមីន ទាក់ទងនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវតែគាំទ្រកម្មវិធីថ្នាក់ជាតិ និងស្របតាមកម្មវិធីរបស់អាជ្ញាធរមីន និងគោលការណ៍ណែនាំ ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

អនុលោមតាមស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះប្រតិបត្តិករសកម្មភាពមីន ឬដៃគូអនុវត្តត្រូវតែ ៖

- ជូនដំណឹងដល់អាជ្ញាធរមីន អំពីកិច្ចខិតខំប្រឹងប្រែងជាក់លាក់លើផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយ

សារមីន

- ប្រមូលទិន្នន័យដោយធ្វើការញែក ភេទ អាយុ និងប្រភេទពិការភាព លើជនរងគ្រោះដោយអនុលោមតាមបទប្បញ្ញត្តិដែលពាក់ព័ន្ធ នឹងកិច្ចការពារទិន្នន័យ និងធានាថាការចែករំលែកទិន្នន័យដែលពាក់ព័ន្ធឱ្យបានសមស្រប
- ប្រមូលទិន្នន័យពាក់ព័ន្ធនឹងសេវាកម្មដែលមានស្រាប់ និងរួមចំណែកដល់ការបង្កើតបញ្ជីសេវាកម្មដោយមានការសម្របសម្រួលជាមួយក្រសួងសុខាភិបាល និងអាជ្ញាធរសុខាភិបាលពាក់ព័ន្ធផ្សេងទៀត ការកំណត់ និងការសម្របសម្រួលដល់ការដឹកជញ្ជូនដើម្បីធ្វើការសង្គ្រោះបន្ទាន់ដល់ប្រជាពលរដ្ឋដែលរងរបួសធ្ងន់ធ្ងរដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ និងអ្នករបួសផ្សេងទៀត ដែលមានការគំរាមកំហែងដល់អាយុជីវិតទៅកាន់មណ្ឌលថែទាំសុខភាពដែលនៅជិតបំផុតនៅក្នុងតំបន់ដែលពួកគេកំពុងប្រតិបត្តិការ
- ទំនាក់ទំនងទីតាំង ដែលការថែទាំវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ គួរតែត្រូវបានពង្រឹងដោយផ្អែកលើទិន្នន័យដែលបានមកពីប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្នាក់ជាតិ នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយយុទ្ធភ័ណ្ឌគ្រឿងផ្ទុះ ទៅកាន់អាជ្ញាធរមីន ដែលជាកន្លែងដែលអាចអនុវត្តបាន។ លើសពីនេះ បង្ហាញពីតម្រូវការរបស់ជនរងគ្រោះធ្ងន់ធ្ងរ អ្នករស់រានមានជីវិត និងជនរងគ្រោះដោយប្រយោល ដោយផ្អែកលើទិន្នន័យដែលមានស្រាប់ដល់ម្ចាស់ជំនួយ។ អាជ្ញាធរមីន និងវិស័យដែលពាក់ព័ន្ធនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភ័ណ្ឌគ្រឿងផ្ទុះ ដើម្បីចូលរួមក្នុងការគាំទ្រដល់អន្តរវិស័យឱ្យកាន់តែទូលំទូលាយ

បន្ថែមលើសពីនេះ ប្រតិបត្តិករសកម្មភាពមីនដែលទទួលថវិកាពីផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដើម្បីផ្តល់សេវាកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវតែៈ

- ជូនដំណឹងដល់អាជ្ញាធរមីន និងសហគមន៍ដែលរងផលប៉ះពាល់អំពីសេវាកម្មនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលគាំទ្រដល់ពួកគាត់
- ធានាថា សេវាដែលពាក់ព័ន្ធនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ស្របតាមស្តង់ដាថ្នាក់ជាតិ ឬអន្តរជាតិ អនុសញ្ញា គោលនយោបាយស្តីពីសុខភាព ការអប់រំ និងសេដ្ឋកិច្ច-សង្គម
- ធានាថា ដៃគូអនុវត្តដែលពាក់ព័ន្ធត្រូវបានចុះបញ្ជីជាមួយក្រសួង ឬស្ថាប័នរបស់រដ្ឋាភិបាលដែលទទួលបន្ទុកក្នុងការពិនិត្យផ្ទៀងផ្ទាត់លើសមត្ថភាព និងទទួលបានការបណ្តុះបណ្តាលសមស្រប មានលក្ខណៈគ្រប់គ្រាន់ និងទទួលបានការបំពាក់បំប៉ន់ត្រឹមត្រូវ
- ធានាថា អ្នករស់រានមានជីវិត និងអង្គភាពតំណាងរបស់ពួកគាត់ត្រូវបានគិតគូរឱ្យចូលរួម និងរួមបញ្ចូលនៅក្នុងសេវាកម្មកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលពួកគាត់បានអនុវត្ត។

### ៦.៣.៣. អង្គការដៃគូ

អង្គការដៃគូ និងសហគមន៍ផ្តល់សេវាកម្មផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

គួរតែអនុវត្តការងារឱ្យស្របតាមណែនាំដែលមានក្នុងឯកសារនេះ ដែលជាគន្លឹះក្នុងការសម្របសម្រួលក្នុងការផ្តល់សេវាកម្មផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះថ្នាក់ជាតិ។ អង្គការនីមួយៗមានកាតព្វកិច្ចរបស់ខ្លួន និងគោលនយោបាយផ្ទៃក្នុង។ម្យ៉ាងវិញទៀត អង្គការគួរតែធានាថាស្តង់ដាជាតិដែលពាក់ព័ន្ធទៅនឹងគោលនយោបាយស្តីពីសុខភាព ការអប់រំ និងសេដ្ឋកិច្ច-សង្គម ត្រូវបានអនុវត្តដើម្បីសម្របសម្រួលសេវាកម្មផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

អង្គការទាំងអស់ ត្រូវជូនដំណឹងដល់អាជ្ញាធរមីន និងសហគមន៍ផ្តល់សេវាកម្ម និងការគាំទ្រលើផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ អង្គការដៃគូត្រូវធានាថា អង្គការ និងបុគ្គលិករបស់ខ្លួនមានជំនាញ ទទួលបានការបណ្តុះបណ្តាល មានសមត្ថភាពគ្រប់គ្រាន់ និងបានបំពាក់បំប៉ន់ត្រឹមត្រូវ។ អង្គការដៃគូតម្រូវឱ្យមានទំនាក់ទំនងការងារល្អ ដោយមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរមីន ជនរងគ្រោះដោយសារមីន និងអ្នកតំណាងរបស់ពួកគាត់ ដើម្បីធានាក្នុងការដាក់បញ្ចូលទៅក្នុងសេវាកម្មកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

## ៦.៤. អង្គការសហប្រជាជាតិ

សកម្មភាពដែលធ្វើឡើងដោយអង្គភាពណាមួយ ដែលជាផ្នែកនៃប្រព័ន្ធអង្គការសហប្រជាជាតិគួរតែរៀបចំយុទ្ធសាស្ត្ររបស់ខ្លួនឱ្យស្របតាមបរិបទរបស់កម្ពុជា និងក្នុងក្របខ័ណ្ឌគោលនយោបាយដែលបង្កើតឡើងដោយរដ្ឋាភិបាល តាមរយៈអាជ្ញាធរមីន។

## ៦.៥. អង្គការផ្សេងៗ

អង្គការ (មិនមែនជាដៃគូ) សូមឱ្យពិចារណាលើការបង្កើតគោលនយោបាយ ឬនីតិវិធីដែលទាក់ទងនឹងការគាំទ្រលើសកម្មភាពកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលត្រូវបានណែនាំឱ្យអង្គការទាំងនោះត្រូវចុះបញ្ជីជាមួយក្រសួង ឬស្ថាប័នរបស់រដ្ឋាភិបាល។

**សេវាកម្មកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះផ្សេងទៀតដែលរួមបញ្ចូល ប៉ុន្តែមិនត្រូវបានកំណត់មាន៖**

- អ្នកផ្តល់សេវា ដូចជាអង្គការក្រៅរដ្ឋាភិបាលដែលជួយដល់ផ្នែកពិការភាព សុខមាលភាព និងអង្គការសហគមន៍ដែលជាកន្លែងផ្តល់ការអប់រំជាដើម
- មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម ដូចជា មណ្ឌលសុខភាព (សាធារណៈ និងឯកជន) មន្ទីរពេទ្យមូលដ្ឋាន អង្គការសុខមាលភាព និងសហគមន៍ កន្លែងផ្តល់ការអប់រំជាដើម
- សេវាកម្ម ឬកម្មវិធីរបស់ក្រសួងសុខាភិបាល
- សេវាកម្ម ឬកម្មវិធីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- មូលនិធិជនពិការ(រដ្ឋាភិបាល) និងសហគមន៍អង្គការក្រៅរដ្ឋាភិបាល
- ក្រុមប្រឹក្សាសកម្មភាពជនពិការ
- និងផ្សេងទៀត។

### ៦.៦. អង្គការអ្នករស់រានមានជីវិត និងអង្គភាពតំណាងរបស់ពួកគាត់

អង្គការដែលធ្វើការជាមួយអ្នករស់រានមានជីវិត និងជនមានពិការភាព (រួមទាំងសមាគមន៍ និងបណ្តាញ) គឺមានសារៈសំខាន់សម្រាប់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ ការងារសំខាន់ៗមួយចំនួនរួមមាន៖

- ផ្សព្វផ្សាយ និងតស៊ូមតិដើម្បីសិទ្ធិមនុស្ស
- ផ្សព្វផ្សាយ និងតស៊ូមតិឱ្យមានការចូលរួមស្មើភាពគ្នា
- ផ្សព្វផ្សាយ និងតស៊ូមតិសម្រាប់ការអនុវត្តឱ្យបានល្អក្នុងមូលដ្ឋាន
- ធានាថាកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះត្រូវបានយល់ដឹងច្បាស់លាស់នៅគ្រប់កម្រិតនៃសកម្មភាពមីន
- ធានាថា កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវបានយល់ដឹងច្បាស់លាស់នៅគ្រប់កម្រិតនៃស្ថាប័នរបស់រដ្ឋាភិបាល និងសង្គម។

អង្គការនៃអ្នករស់រានមានជីវិត និងអង្គការដែលគាំទ្រដល់ជនមានពិការភាពត្រូវបានទទួលស្គាល់ថា មានទស្សនវិស័យ ជាពិសេសលើស្ថានភាពរបស់ពួកគេ និងតម្រូវការរបស់ពួកគេដែលទាក់ទងទៅនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ ដូចនេះ វាត្រូវបានស្នើសុំឱ្យអង្គការទាំងនេះស្វែងរក និងឆ្លើយតបយ៉ាងសកម្មចំពោះសកម្មភាពក្នុងការរៀបចំផែនការ ការសម្របសម្រួល ការអនុវត្ត ការត្រួតពិនិត្យ ការវាយតម្លៃ និងការរាយការណ៍។

## ៧. សេចក្តីសន្និដ្ឋាន

ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ផ្តល់នូវក្របខ័ណ្ឌគាំទ្រដល់ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ និងសហគមន៍ នៅក្រោមស្តង់ដាអន្តរជាតិ ដូចជាធម្មនុញ្ញសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ រួមជាមួយនឹងគោលបំណងរបស់រដ្ឋាភិបាលកម្ពុជា ដែលគ្របដណ្តប់នៅក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គ្របដណ្តប់លើគោលការណ៍សមាសភាគសំខាន់ៗ និងតួនាទី និងការទទួលខុសត្រូវរបស់អង្គការនៅក្នុងផ្តល់សេវាកម្ម ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

នៅក្នុងប្រទេសកម្ពុជាយុទ្ធភណ្ឌគ្រឿងផ្ទុះ បានបង្កឱ្យប៉ះពាល់ដល់មនុស្សគ្រប់រូបនៅក្នុងសហគមន៍ ដូចនេះ ហើយវាជាការសំខាន់ណាស់ ដែលត្រូវប្រកាន់យកនូវវិធីសាស្ត្ររួមមួយចំពោះសកម្មភាពមីនទាំងអស់ រួមទាំងការធ្វើផែនការ ការកំណត់អាទិភាព ការស្រាវជ្រាវ ការប្រមូលទិន្នន័យ កិច្ចប្រតិបត្តិការបោសសម្អាត និងការតស៊ូមតិ។ បន្ថែមលើសពីនេះ កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចាំបាច់ត្រូវរៀបចំឡើងដើម្បីធានាថា ក្រុមងាយរងគ្រោះបានចូលរួម ការចូលរួមចំណែក កង្វល់ និងតម្រូវការរបស់ពួកគាត់ត្រូវបានទទួលស្គាល់ និងដោះស្រាយដោយមិនមានភាពលម្អៀង ឬការរើសអើងនោះទេ។

ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះផ្តល់ជាទិសដៅសម្រាប់រៀបចំវិធីសាស្ត្រអន្តរវិស័យរួមបញ្ចូលគ្នាដែលមានអាជ្ញាធរមីន ប្រតិបត្តិករ និងអង្គការផ្សេងទៀត

ផ្តល់នូវក្របខ័ណ្ឌសម្រាប់អនុវត្តដល់អង្គការ ដែលប្រតិបត្តិការទាក់ទងទៅនឹងកិច្ចសង្គ្រោះជនរងគ្រោះដោយសារមីន ដើម្បីសម្របសម្រួល និងដាក់សកម្មភាពបញ្ចូលគ្នា ដោយរួមបញ្ចូលសម្រាប់វិស័យពិការភាព និងភាគីពាក់ព័ន្ធក្នុងការជួយសង្គ្រោះបន្ទាន់ និងថែទាំសុខភាពបន្ត ការស្តារលទ្ធភាពពលកម្ម ការគាំទ្រផ្នែកចិត្តសាស្ត្រ និងចិត្តសង្គម ការប្រមូលទិន្នន័យ ច្បាប់ និងគោលនយោបាយ។

អាជ្ញាធរមីនបន្តធ្វើការលើកកម្ពស់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះសម្រាប់វិស័យ និងភាគីពាក់ព័ន្ធនៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រថ្នាក់ជាតិនៅក្នុងកម្មវិធីសកម្មភាពមីន។ អាជ្ញាធរមីនរំពឹងថានឹងមានការប្តេជ្ញាចិត្តស្រដៀងគ្នាពីអង្គការសកម្មភាពមីនទាំងអស់នៅកម្ពុជា។ អាជ្ញាធរមីនធ្វើការលើកទឹកចិត្ត និងផ្តល់នូវធនធានដល់អង្គការសកម្មភាពមីននៅក្នុងប្រទេសកម្ពុជា។ ភាគីពាក់ព័ន្ធត្រូវបានណែនាំឱ្យអនុវត្តស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជាស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ឱ្យអស់ពីលទ្ធភាព ដើម្បីធានាបាននូវភាពជោគជ័យក្នុងការអនុវត្តសកម្មភាព និងផ្តល់សេវាកម្មកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ បន្ថែមលើសពីនេះ អង្គការសកម្មភាពមីនគួរតែចូលរួមចំណែកក្នុងការសម្រេចឱ្យបាននូវគោលដៅនៃយុទ្ធសាស្ត្រជាតិសកម្មភាពមីនដើម្បីឈានទៅរកអនាគតដ៏ល្អប្រសើរសម្រាប់ប្រជាជនកម្ពុជា។

អាជ្ញាធរមីនផ្តល់ឯកសារនេះ ជាមគ្គុទ្ទេសក៍ទូទៅមួយ ដើម្បីជួយដល់ក្រសួង ស្ថាប័ន អង្គភាព និងអង្គការពាក់ព័ន្ធ ដែលជួយគាំទ្រជនរងគ្រោះដោយសារមីន និងយុទ្ធភណ្ឌគ្រឿងផ្ទុះ។

<u>ឯកសារភ្ជាប់</u>៖

**ឧបសម្ព័ន្ធ១៖ កំណត់ត្រាអំពីការកែលម្អ**

**ឧបសម្ព័ន្ធ២៖ ឯកសារយោង**

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានី ភ្នំពេញ ថ្ងៃទី ខែធ្នូ ឆ្នាំ២០២៤

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានទី១**

**ឧបសម្ព័ន្ធ១**

# កំណត់ត្រាអំពីការកែលម្អ

ការគ្រប់គ្រងការកែលម្អស្តង់ដា

ស្តង់ដានីមួយៗចាំបាច់ត្រូវពិនិត្យឡើងវិញជាផ្លូវការរៀងរាល់ ៥ឆ្នាំ ម្តង។ ទោះជាយ៉ាងនេះក្តី ការពិនិត្យ ឬ កែសម្រួលឡើងវិញអាចធ្វើឡើងមុនពេលកំណត់ ក្នុងគោលបំណងពង្រឹងសុវត្ថិភាពប្រតិបត្តិការ ប្រសិទ្ធភាព និង ប្រសិទ្ធផល ។

នៅពេលធ្វើការកែលម្អស្តង់ដា យើងត្រូវផ្តល់លេខ ចុះកាលបរិច្ឆេទ និងរៀបរាប់ទូទៅអំពីការកែលម្អក្នុង តារាងខាងក្រោម។ លេខកែលម្អនឹងមានបង្ហាញលើក្របទំព័រខាងមុខនៃស្តង់ដានេះ។

| លេខ | កាលបរិច្ឆេទ | ព័ត៌មានលម្អិតអំពីវិសោធនកម្ម |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

## ឧបសម្ព័ន្ធ២៖ ឯកសារយោង

១. ស្តង់សកម្មភាពកំចាត់មីនអន្តរជាតិលេខ ១៣.១

២. ផែនការជាតិសកម្មភាពមីនឆ្នាំ២០១៨-២០២៥

៣. ផែនការជាតិស្តីពីពិការភាពឆ្នាំ២០១៩-២០២៣

៤. ផែនការយុទ្ធសាស្ត្ររបស់អង្គការសហប្រជាជាតិស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារមីន

៥. អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្ម តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន

៦. អនុក្រឹត្យស្តីពីការកំណត់អត្រា និងបែបបទនៃការជ្រើសជនពិការចូលបម្រើការងារ

៧. អនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍

៨. ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម

៩. បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព

១០. អនុសញ្ញាស្តីពីសិទ្ធិជនពិការ

១១. អនុសញ្ញាស្តីពីការហាមប្រាម ការប្រើប្រាស់ ការរក្សា ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីនចោល (អនុសញ្ញាអូតាវ៉ា)

១២. ផែនការសកម្មភាពអូស្លូ ឆ្នាំ២០២០-២០២៤